ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីតាមដាន និង ទប់ស្កាត់ ជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARS)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីតាមដាន និង ទប់ស្កាត់ ជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARS) ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម រដ្ឋមន្ត្រី | ក្រសួងសុខាភិបាល | ប្រធាន |
| ២. ឯកឧត្តម សហរដ្ឋមន្ត្រី ឬ តំណាង | ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦. ឯកឧត្តម សហរដ្ឋមន្ត្រី ឬ តំណាង | ក្រសួងការពារជាតិ | សមាជិក |

4

| | | |
|---|---|---|
| ៧. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងអប់រំយុវជន និង កីឡា | សមាជិក |
| ៨. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៩. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងពត៌មាន | សមាជិក |
| ១០. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងសង្គមកិច្ច ការងារ បណ្តុះ បណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ១១. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. ឯកឧត្តម រដ្ឋមន្ត្រី ឬ តំណាង | ក្រសួងសាធារណៈការ និង ដឹកជញ្ជូន | សមាជិក |
| ១៣. ឯកឧត្តមរដ្ឋលេខាធិការឬតំណាង | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| ១៤. ឯកឧត្តម អភិបាលខេត្ត/ក្រុងដែលមានការពាក់ព័ន្ធ | | សមាជិក |
| ១៥. នាយកដ្ឋានប្រយុទ្ធនឹងជម្ងឺឆ្លងនៃក្រសួងសុខាភិបាល | | លេខាធិការ |

**ប្រការ ២** : គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅៈ

- សំរបសំរួលសកម្មភាពអន្តរក្រសួង
- កំណត់គោលនយោបាយលើការត្រៀមរៀបចំ និង មធ្យោបាយដ៏មានប្រសិទ្ធិភាព ដើម្បីទប់ស្កាត់ជំងឺ SARS
- ផ្តល់ជូនថ្នាក់ដឹកនាំកំពូលជាទៀងទាត់ នូវពត៌មានថ្មីៗ ស្តីពីសភាពការណ៍បច្ចុប្បន្ន របស់ស្ថាប័នទាំងអស់ ដែលពាក់ព័ន្ធនឹងជំងឺ SARS
- ជំរុញការអនុវត្តន៍ រាល់សេចក្តីសំរេច ដើម្បីតាមដាន និង ទប់ស្កាត់ជំងឺ SARS ទៅតាមភារកិច្ចរបស់ស្ថាប័ននីមួយៗ
- សិក្សាស្រាវជ្រាវ ពីផលប៉ះពាល់ សង្គម និង សេដ្ឋកិច្ច ដែលបណ្តាលមកពីជម្ងឺ SARS
- ចាត់វិធានការណ៍គ្រប់បែបយ៉ាងដើម្បីធានាសុខភាពជូនប្រជាពលរដ្ឋការពារ និង ការរាតត្បាតនៃជម្ងឺ SARS

**ប្រការ៣** : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិរៀបចំលេខាធិការដ្ឋានមួយ ដើម្បីជំនួយការងារដែលមានទីតាំង និង សមាសភាពកំណត់ដោយប្រធានគណៈកម្មការ និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល។

/ /.

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ  សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ  សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណៈការ និង ដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និង សមាសភាពដូចចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *ឯកសារ_កាលប្បវត្តិ*